# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
និង
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្ម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា តីអិលស៊ី

## មាតិកា

*ទំព័រ*


របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ 1 – 5

របាយការណ៍របស់សវនករឯករាជ្យ ........ 6 – 9

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ 10

របាយការណ៍លទ្ធផលពេញលេញ ........ 11

របាយការណ៍បម្រែបម្រួលមូលធន ........ 12

របាយការណ៍លំហូរសាច់ប្រាក់ ........ 13 – 14

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ........ 15 – 57

MAXIMA
Microfinance

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

MAXIMA Microfinance Plc.

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) សូមបង្ហាញរបាយការណ៍របស់ខ្លួនជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រ ដែលសេវាកម្មទាំងនោះរួមមាន ការផ្តល់ឥណទានទៅដល់គ្រួសារក្រីក្រ និងគ្រួសារមានចំណូលទាប និងសហគ្រាសខ្នាតតូចដែលកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### ភាគលាភ

ពុំមានការប្រកាស ឬបែងចែកភាគលាភឡើយ ហើយអភិបាល ក៏ពុំមានអនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

### ដើមទុន

មិនមានការផ្លាស់ប្តូរនៃដើមទុនសរុប របស់ក្រុមហ៊ុននៅក្នុងឆ្នាំទេ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធភាគទុនិក ត្រូវបានបង្ហាញនៅកំណត់សម្គាល់លេខ 15 នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ទុនបម្រុង និងសំវិធានធន

ពុំមានបម្រែបម្រួលជាសារវន្តទៅ ឬចេញពីទុនបម្រុង និងសំវិធានធន នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

### ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីធ្វើឱ្យប្រាកដថាសកម្មភាពទាក់ទិននឹងការជម្រះឥណទានអាក្រក់ចេញពីបញ្ជី និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ ត្រូវបានជម្រះបញ្ជី ហើយសំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់។



អគារ The Kampus លេខ០៨៤១ ជាន់ទី១ បន្ទប់លេខ ១ហាស ផ្លូវព្រះមុនីវង្ស ភូមិ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ គេហទំព័រ www.maxima.com.kh អ៊ីម៉ែល info@maxima.com.kh ទូរស័ព្ទ ០៩៨ ២១៤ ២៤០
Kampus building, N° 0841, 1st Floor, Unit N° 1H, Preah Monivong Blvd., Phum 4, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh 120101, Email: info@maxima.com.kh, Phone ( +855-98 ) 214 240

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

**ឥណទានអាក្រក់ និងជាប់សង្ស័យ** (តពីទំព័រមុន)

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលអាចបណ្តាលឱ្យចំនួននៃឥណទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនលើឥណទានដែលជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

**ទ្រព្យសកម្ម**

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ សមស្របនានា ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងអស់ ក្រៅពីឥណទាន និងបុរេប្រទាន ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដូចដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាឱ្យនៅត្រឹមស្មើតម្លៃដែលនឹងរំពឹងថាអាចប្រមូលបាន។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ គណៈគ្រប់គ្រង ពុំបានដឹងពីកាលៈទេសៈណាមួយដែលនឹងបណ្តាលឱ្យការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវនោះទេ។

**វិធីសាស្ត្រវាយតម្លៃ**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលបានកើតឡើងហើយធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

**បំណុលយថាហេតុ និងបំណុលផ្សេងៗ**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយចំពោះក្រុមហ៊ុនដែលកើតមានឡើង ចាប់តាំងពីថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុននោះឡើយ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ដែលនឹងបង្កឱ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ឡើយ។

**ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍ជាសារវន្តណាមួយ កើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលនឹងតម្រូវឱ្យមាននិយ័តកម្ម ឬការបង្ហាញព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### ធាតុមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះ មិនបានរងផលប៉ះពាល់ដោយធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយជាសារវន្ត និងមានលក្ខណៈមិនប្រក្រតីទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានធាតុណាមួយ សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយនៅចន្លោះថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ មានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ហើយបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះត្រូវបានរៀបចំឡើងនោះទេ។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| លោក ប៉ា ប៊ុណ្ណរិទ្ធី | ប្រធានក្រុមប្រឹក្សាភិបាល *(តែងតាំងនៅថ្ងៃទី28 ខែតុលា ឆ្នាំ2025)* |
| លោក អន ប៊ុនហាក់ | ប្រធានក្រុមប្រឹក្សាភិបាល *(លាលែងនៅថ្ងៃទី28 ខែតុលា ឆ្នាំ2025)* |
| លោក Guerol Michael Sari | សមាជិកក្រុមប្រឹក្សាភិបាល *(តែងតាំងនៅថ្ងៃទី28 ខែតុលា ឆ្នាំ2025)* |
| លោកស្រី Vidary Inthamone | សមាជិកក្រុមប្រឹក្សាភិបាល *(តែងតាំងនៅថ្ងៃទី28 ខែតុលា ឆ្នាំ2025)* |
| លោក Taejun Shin | សមាជិកក្រុមប្រឹក្សាភិបាល *(លាលែងនៅថ្ងៃទី28 ខែតុលា ឆ្នាំ2025)* |
| លោក Sanjay Gandhi | សមាជិកក្រុមប្រឹក្សាភិបាល *(លាលែងនៅថ្ងៃទី28 ខែតុលា ឆ្នាំ2025)* |
| លោក Forsinetti Christophe | អភិបាលឯករាជ្យ |
| លោកស្រី Ewa Janikowska | អភិបាលឯករាជ្យ |

### ភាគហ៊ុនរបស់អភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ កាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនទេ។

### អត្ថប្រយោជន៍របស់អភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់អភិបាលរបស់ក្រុមហ៊ុនឱ្យទទួលបាននូវអត្ថប្រយោជន៍ តាមមធ្យោបាយនៃការទិញភាគហ៊ុនរបស់ក្រុមហ៊ុននោះឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានអភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបដែលទទួល ឬដល់កាលកំណត់ និងត្រូវទទួលបានដោយអភិបាល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនដែលអភិបាលនោះជាសមាជិក ឬធ្វើឡើងជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ ក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានតួនាទីក្នុងការធានាថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងលទ្ធផលហិរញ្ញវត្ថុ ហើយនិងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រង ដែលតម្រូវឱ្យ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តជាប់ជាប្រចាំ

(ខ) អនុលោមតាម CIFRS for SMEs ឬ ប្រសិនបើមានការប្រាសចាកណាមួយ សម្រាប់គោលបំណងនៃការបង្ហាញនូវភាពពិតនិងត្រឹមត្រូវ ការប្រាសចាកនេះត្រូវបានលាតត្រដាង បកស្រាយ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានសមរម្យក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត និង

(ង) ដាក់ចេញនូវគោលនយោបាយរួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់ការសម្រេចចិត្ត និងសកម្មភាពទាំងឡាយ ដែលអាចប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យត្រឹមត្រូវ ត្រូវបានរក្សាទុក និងលាតត្រដាងអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ហើយនិងធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលត្រូវអនុវត្ត។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុន ហើយម្យ៉ាងទៀតក៏ត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ ហើយនិងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាល បញ្ជាក់ថាក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដូចដែលមានភ្ជាប់ជាមួយនេះ ថាបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាម CIFRS for SMEs ។

ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាល ដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី
MAXIMA Microfinance Plc.
KINGDOM OF CAMBODIA

លោក ប៉ា ប៉ុណ្ណរិទ្ធី
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី10 ខែមេសា ឆ្នាំ2026

EY
Shape the future with confidence

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
64 Preah Norodom Boulevard
Corner Street 178, Sangkat Chey Chumneah
Khan Daun Penh, Phnom Penh, Cambodia

Tel: +855 23 860 450/451
Email: eykoc@kh.ey.com
Website: ey.com/en_kh

យោង: 13858159/69217658

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ៖ ភាគទុនិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

### *មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងរបាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

### *មូលដ្ឋានក្នុងការផ្តល់មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដាទាំងនោះ ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ "*ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*" នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយយោងទៅតាមប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា ជាមួយនឹងតម្រូវការផ្នែកសីលធម៌ដែលពាក់ព័ន្ធនឹងការងារសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំ ក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌របស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះផងដែរ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។

### *បញ្ហាផ្សេងៗ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិយោបល់ត្រឹមត្រូវលើរបាយការណ៍ទាំងនោះ នៅថ្ងៃទី10 ខែមេសា ឆ្នាំ2025។



A member firm of Ernst & Young Global Limited

### ព័ត៌មានផ្សេងៗ

ព័ត៌មានផ្សេងៗដែលទទួលបាន នាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រង មានទំនួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានជានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពខុសគ្នាជាសារវន្តឬទេ ជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការធ្វើសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះមានកំហុសឆ្គងជាសារវន្តឬទេ។ ដោយផ្អែកលើការងារដែលបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំតម្រូវឱ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាម CIFRS for SMEs និងទទួលខុសត្រូវផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គណៈគ្រប់គ្រងមានទំនួលខុសត្រូវលើការវាយតម្លៃលទ្ធភាពនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាងព័ត៌មាន (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធានគណនេយ្យ លើកលែងតែក្នុងករណី គណៈគ្រប់គ្រងមានបំណងចង់រំលាយ ឬបញ្ឈប់ដំណើរការប្រតិបត្តិការរបស់ក្រុមហ៊ុន ឬក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវលើការត្រួតពិនិត្យមើលដំណើរការ ការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

### ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផល គឺជាការអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា ការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្តដែលបានកើតឡើងនោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាមានភាពជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬបញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។



A member firm of Ernst & Young Global Limited

***ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ជាផ្នែកមួយនៃការងារសវនកម្ម ដោយអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈ ក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យ ដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានកម្រិតខ្ពស់ជាង ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬមិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណង ដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធានគណនេយ្យរបស់គណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន ថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត ទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌទាំងឡាយណាដែលនាំឱ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនឬទេ។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឱ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍របស់សវនករ លើកំណត់សម្គាល់ដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទ នៃរបាយការណ៍របស់សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ និងលក្ខខណ្ឌនាពេលអនាគតក៏អាចបង្កឱ្យក្រុមហ៊ុនមិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃលើការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងការលាតត្រដាងផ្សេងៗ និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុតំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។



A member firm of Ernst & Young Global Limited

Shape the future
with confidence

***ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកនៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ ដែលរួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ខារ ហុង

Partner

**អឺនស្ទ៍ អែន យ៉ាំង (ខេមបូឌា)**

ក្រុមហ៊ុនគណនេយ្យករជំនាញ

សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី10 ខែមេសា ឆ្នាំ2026



A member firm of Ernst & Young Global Limited

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា អឹមអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *កំណត់សម្គាល់* | *2025* | | *2024* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 4 | 4,186 | 16,798 | 3,159 | 12,716 |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | 5 | 1,314,601 | 5,275,494 | 913,283 | 3,675,964 |
| សមតុល្យនៅធនាគារជាតិ នៃកម្ពុជា | 6 | 275,090 | 1,103,936 | 257,004 | 1,034,441 |
| ឥណទានទៅអតិថិជនសុទ្ធ | 7 | 19,376,786 | 77,759,042 | 23,842,035 | 95,964,190 |
| ការវិនិយោគលើមូលធន | 8 | 10,000 | 40,130 | 10,000 | 40,250 |
| ទ្រព្យសកម្មផ្សេងៗ | 9 | 223,449 | 896,701 | 182,077 | 732,861 |
| ទ្រព្យ និងបរិក្ខារ | 10 | 97,627 | 391,777 | 132,797 | 534,508 |
| ទ្រព្យសកម្មអរូបី | 11 | 19,338 | 77,603 | 14,085 | 56,692 |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | 18ឃ | 172,312 | 691,488 | 172,312 | 693,556 |
| **ទ្រព្យសកម្មសរុប** | | **21,493,389** | **86,252,969** | **25,526,752** | **102,745,178** |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | 12 | 14,423,671 | 57,882,192 | 18,723,783 | 75,363,227 |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | 13 | 19,374 | 77,748 | 9,660 | 38,882 |
| បំណុលផ្សេងៗ | 14 | 307,985 | 1,235,942 | 456,267 | 1,836,475 |
| **បំណុលសរុប** | | **14,751,030** | **59,195,882** | **19,189,710** | **77,238,584** |
| **មូលធន** | | | | | |
| ដើមទុន | 15ក | 5,095,290 | 20,569,686 | 5,095,290 | 20,569,686 |
| បុព្វលាភភាគហ៊ុន | 15ខ | 1,538,174 | 6,209,608 | 1,538,174 | 6,209,608 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 16 | 13,146 | 45,172 | 10,092 | 32,922 |
| ចំណូលទុនបម្រុង | 17 | 133,424 | 538,428 | 133,424 | 538,428 |
| ខាតបង្គរ | | (37,675) | (270,774) | (439,938) | (1,884,250) |
| លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ | | - | (35,033) | - | 40,200 |
| **មូលធនសរុប** | | **6,742,359** | **27,057,087** | **6,337,042** | **25,506,594** |
| **បំណុល និងមូលធនសរុប** | | **21,493,389** | **86,252,969** | **25,526,752** | **102,745,178** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

## របាយការណ៍លទ្ធផលពេញលេញ
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *កំណត់សម្គាល់* | *2025* | | *2024* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2) (បានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ 31)* |
| ចំណូលការប្រាក់ | 19 | 4,134,787 | 16,584,631 | 5,052,418 | 20,568,394 |
| ចំណាយការប្រាក់ | 20 | (1,811,819) | (7,267,206) | (2,262,426) | (9,210,336) |
| **ចំណូលការប្រាក់សុទ្ធ** | | **2,322,968** | **9,317,425** | **2,789,992** | **11,358,058** |
| កម្រៃ និងចំណូលជើងសារ | 21 | 976,837 | 3,918,093 | 573,307 | 2,333,933 |
| ចំណូលផ្សេងៗ | 22 | 168,297 | 675,039 | 177,859 | 724,064 |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | | 12,840 | 51,501 | 68,741 | 279,845 |
| **ចំណូលប្រតិបត្តិការសុទ្ធ** | | **3,480,942** | **13,962,058** | **3,609,899** | **14,695,900** |
| ខាតអ៊ីមភែរមិនសុទ្ធ លើឥណទានទៅអតិថិជន | 7 | (103,958) | (416,976) | (2,621,874) | (10,673,649) |
| ចំណាយបុគ្គលិក | 23 | (2,216,106) | (8,888,801) | (2,104,262) | (8,566,451) |
| ចំណាយរំលស់ | 24 | (52,950) | (212,382) | (49,023) | (199,573) |
| ចំណាយប្រតិបត្តិការ | 25 | (702,611) | (2,818,173) | (858,103) | (3,493,337) |
| **ចំណេញ (ខាត) មុនគិតពន្ធលើប្រាក់ចំណូល** | | **405,317** | **1,625,726** | **(2,023,363)** | **(8,237,110)** |
| ឥណទានពន្ធលើប្រាក់ចំណូល | 18ខ | - | - | 39,784 | 161,961 |
| **ចំណេញ (ខាត) សុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **405,317** | **1,625,726** | **(1,983,579)** | **(8,075,149)** |
| *ខាតពេញលេញផ្សេងៗ៖* | | | | | |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | (75,233) | - | (407,994) |
| **ចំណេញ (ខាត) ពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ** | | **405,317** | **1,550,493** | **(1,983,579)** | **(8,483,143)** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា តីអិលស៊ី

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *ដើមទុន* | | *បុព្វលាភភាគហ៊ុន* | | *ទុនបម្រុងតាមបទប្បញ្ញត្តិ* | | *ចំណូលទុនបម្រុង* | | *ខាតបង្គរ* | | *លម្អៀងបង្គរពីការបកប្រែរូបិយប័ណ្ណ* | *សរុប* | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | **5,095,290** | **20,569,686** | **1,538,174** | **6,209,608** | **10,092** | **32,922** | **133,424** | **538,428** | **(439,938)** | **(1,884,250)** | **40,200** | **6,337,042** | **25,506,594** |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | - | - | 405,317 | 1,625,726 | - | 405,317 | 1,625,726 |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | (75,233) | - | (75,233) |
| **ចំណេញពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **405,317** | **1,625,726** | **(75,233)** | **405,317** | **1,550,493** |
| ផ្ទេរពីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 3,054 | 12,250 | - | - | (3,054) | (12,250) | - | - | - |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025** | **5,095,290** | **20,569,686** | **1,538,174** | **6,209,608** | **13,146** | **45,172** | **133,424** | **538,428** | **(37,675)** | **(270,774)** | **(35,033)** | **6,742,359** | **27,057,087** |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | **5,095,290** | **20,569,686** | **1,538,174** | **6,209,608** | **152,502** | **612,673** | **133,424** | **538,428** | **1,401,231** | **5,611,148** | **448,194** | **8,320,621** | **33,989,737** |
| ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | - | - | (1,983,579) | (8,075,149) | - | (1,983,579) | (8,075,149) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | (407,994) | - | (407,994) |
| **ខាតពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ** | **-** | **-** | **-** | **-** | **-** | **-** | **-** | **-** | **(1,983,579)** | **(8,075,149)** | **(407,994)** | **(1,983,579)** | **(8,483,143)** |
| ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅខាតបង្គរ | - | - | - | - | (142,410) | (579,751) | - | - | 142,410 | 579,751 | - | - | - |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | **5,095,290** | **20,569,686** | **1,538,174** | **6,209,608** | **10,092** | **32,922** | **133,424** | **538,428** | **(439,938)** | **(1,884,250)** | **40,200** | **6,337,042** | **25,506,594** |

*កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *កំណត់សម្គាល់* | *2025* | | *2024* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញ (ខាត) សុទ្ធសម្រាប់ការិយបរិច្ឆេទ | | 405,317 | 1,625,726 | (1,983,579) | (8,075,149) |
| និយ័តកម្មលើ៖ | | | | | |
| ឥណទានពន្ធលើប្រាក់ចំណូល | 18ខ | - | - | (39,784) | (161,961) |
| ខាតអ៊ីមភែរមិនសុទ្ធ លើឥណទានទៅអតិថិជន | 7 | 263,848 | 1,058,294 | 2,676,386 | 10,895,567 |
| កាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | | 9,714 | 38,963 | - | - |
| ចំណាយរំលស់ | 24 | 52,950 | 212,382 | 49,023 | 199,573 |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | | (8,226) | (32,994) | (1,118) | (4,551) |
| | | **723,603** | **2,902,371** | **700,928** | **2,853,479** |
| បម្រែបម្រួលនូវ៖ | | | | | |
| ឥណទានទៅអតិថិជន | | 4,201,401 | 16,851,819 | 3,915,875 | 15,941,527 |
| ទ្រព្យសកម្មផ្សេងៗ | | 3,633 | 14,572 | 177 | 721 |
| បំណុលផ្សេងៗ | | 194,067 | 778,403 | 32,041 | 130,439 |
| **សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ** | | **5,122,704** | **20,547,165** | **4,649,021** | **18,926,166** |
| ពន្ធលើប្រាក់ចំណូលបានបង់ | 18គ | (45,005) | (180,515) | (58,580) | (238,479) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | | **5,077,699** | **20,366,650** | **4,590,441** | **18,687,687** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

**របាយការណ៍លំហូរសាច់ប្រាក់** (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | *កំណត់សម្គាល់* | *2025* | | *2024* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញ៖ | | | | | |
| ទ្រព្យ និងបរិក្ខារ | 10 | (12,743) | (51,112) | (93,090) | (378,969) |
| ទ្រព្យសកម្មអរូបី | 11 | (11,299) | (45,320) | - | - |
| សាច់ប្រាក់ទទួលបានពីការលក់ ទ្រព្យ និងបរិក្ខារ | | 9,235 | 37,042 | 1,118 | 4,551 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(14,807)** | **(59,390)** | **(91,972)** | **(374,418)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 12 | 4,496,761 | 18,036,508 | 6,200,000 | 25,240,200 |
| ការទូទាត់ប្រាក់កម្ចី | 12 | (9,139,222) | (36,657,419) | (13,660,426) | (55,611,594) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | **(4,642,461)** | **(18,620,911)** | **(7,460,426)** | **(30,371,394)** |
| **ការកើនឡើង (ថយចុះ) សុទ្ធនៃ សាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **420,431** | **1,686,349** | **(2,961,957)** | **(12,058,125)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី1 ខែមករា | | 918,681 | 3,697,692 | 3,880,638 | 15,852,407 |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | (10,185) | - | (96,590) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី31 ខែធ្នូ** | 26 | **1,339,112** | **5,373,856** | **918,681** | **3,697,692** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

## 1. ព័ត៌មានរបស់ក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលមានឈ្មោះដើមថា អង្គការម៉ាក់ស៊ីម៉ាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ហៅកាត់ថា ("ស្ថាប័ន") ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា និងចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី27 ខែកក្កដា ឆ្នាំ2005 ក្រោមលិខិតចុះបញ្ជីលេខ 00005996 (ពីមុនលេខ Co. 7897E/2005)។ នៅថ្ងៃទី10 ខែសីហា ឆ្នាំ2005 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណអាជីវកម្មលេខ 013 ពីធនាគារជាតិនៃកម្ពុជា សម្រាប់ធ្វើប្រតិបត្តិការអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីផ្តល់នូវសេវាមីក្រូហិរញ្ញវត្ថុទៅឲ្យប្រជាជនក្រីក្រក្នុងប្រទេសកម្ពុជា។ នៅថ្ងៃទី22 ខែកុម្ភៈ ឆ្នាំ2012 ធនាគារជាតិនៃកម្ពុជា ផ្តល់អាជ្ញាប័ណ្ណអាជីវកម្មអចិន្ត្រៃយ៍លេខ ម.ហ 013 ជូនដល់ក្រុមហ៊ុន ហើយបានកែប្រែឈ្មោះរបស់ខ្លួនទៅជា ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ នៅថ្ងៃទី22 ខែកក្កដា ឆ្នាំ2015 ធនាគារជាតិ នៃកម្ពុជា បានអនុម័តលើការកែសម្រួលឈ្មោះថ្មីរបស់ក្រុមហ៊ុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រ ដែលសេវាកម្មទាំងនោះរួមមាន ការផ្តល់ឥណទានទៅដល់គ្រួសារក្រីក្រ និងគ្រួសារមានចំណូលទាប និងសហគ្រាសខ្នាតតូចដែលកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាស័យដ្ឋានរបស់ទីស្នាក់ការចុះបញ្ជី និងទីកន្លែងអាជីវកម្មចម្បងរបស់ក្រុមហ៊ុន មានទីតាំងនៅ អគារលេខ 0841 ជាន់ទី1 បន្ទប់លេខ ១ហាស មហាវិថីព្រះមុន្នីវង្ស ភូមិ4 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមានសាខាតាមខេត្តចំនួន 12 ដែលមានទីតាំងនៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តព្រៃវែង ខេត្តកំពត ខេត្តសៀមរាប និងទីស្នាក់ការកណ្តាលមួយ នៅរាជធានីភ្នំពេញ។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ក្រុមហ៊ុនមានបុគ្គលិកសរុបចំនួន 232នាក់ (2024៖ ចំនួន 229នាក់)។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ដោយយោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃទី10 ខែមេសា ឆ្នាំ2026។

## 2. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ

*របាយការណ៍អនុលោមភាព*

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

*ឆ្នាំសារពើពន្ធ*

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុន ចាប់ផ្តើមនៅថ្ងៃទី1 ខែមករា និងបញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

*មូលដ្ឋាននៃការរៀបចំ*

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងតាមមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។

## 2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

### *រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ*

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនជាពីររូបិយប័ណ្ណគឺ ខ្មែររៀល និងដុល្លារអាមេរិក ។ គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញរបស់ក្រុមហ៊ុន ព្រោះវាឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ រាល់តួលេខទាំងអស់ត្រូវបានបង្គត់ទៅជាចំនួនគត់ដុល្លារអាមេរិក ឬពាន់រៀលដែលនៅជិតបំផុត លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។

### *ការបកប្រែរូបិយប័ណ្ណដុល្លារអាមេរិកទៅជាខ្មែររៀល*

ការបកប្រែរូបិយប័ណ្ណដុល្លារអាមេរិក ទៅជាពាន់រៀល ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដោយប្រើប្រាស់អត្រាចុងគ្រា និងអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់។

ទ្រព្យសកម្ម និងបំណុល ត្រូវបានបកប្រែតាមអត្រាចុងគ្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងធាតុមូលធនផ្សេងៗ ត្រូវបានបកប្រែតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍លទ្ធផលពេញលេញ និងលំហូរសាច់ប្រាក់ ត្រូវបានបកប្រែទៅជាខ្មែររៀល ដោយប្រើប្រាស់អត្រាមធ្យមសម្រាប់ការិយបរិច្ឆេទ ដែលអត្រានេះត្រូវបានចាត់ទុកថាមានលក្ខណៈប្រហាក់ប្រហែលនឹងអត្រាបកប្រែរូបិយប័ណ្ណនៅកាលបរិច្ឆេទប្រតិបត្តិការ ព្រោះអត្រាបកប្រែរូបិយប័ណ្ណនេះមិនមានការប្រែប្រួលខ្លាំងនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការបកប្រែរូបិយប័ណ្ណ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ការបកប្រែរូបិយប័ណ្ណមិនគួរត្រូវបានបកស្រាយថា ចំនួនដុល្លារអាមេរិកតំណាងឱ្យ ឬអាចត្រូវបានបកប្រែទៅជាខ្មែររៀលក្នុងអត្រាណាមួយផ្សេងពីអត្រាដែលបានកំណត់នោះទេ។ ទឹកប្រាក់ជាខ្មែររៀល ត្រូវបានបង្គត់ទៅជាខ្ទង់ពាន់រៀល ដែលនៅជិតបំផុត លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាខ្មែររៀល ដោយផ្អែកលើអត្រាប្តូរប្រាក់ដែលត្រូវអនុវត្តក្នុង 1 ដុល្លារអាមេរិកដូចខាងក្រោម៖

| | *2025* | *2024* |
|---|---|---|
| អត្រាចុងគ្រា | 4,013 | 4,025 |
| អត្រាមធ្យម | 4,011 | 4,071 |

គោលនយោបាយគណនេយ្យខាងក្រោមនេះ ត្រូវបានក្រុមហ៊ុនអនុវត្តជាប់ជាប្រចាំក្នុងការិយបរិច្ឆេទ។

## 2. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

*ឧបករណ៍ហិរញ្ញវត្ថុ*

*(i). ការទទួលស្គាល់*

ក្រុមហ៊ុនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដំបូង នៅពេលដែលក្រុមហ៊ុនក្លាយជាភាគីនៃកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុនោះ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃទីផ្សារ បូកនឹងថ្លៃដើមប្រតិបត្តិការ ដែលបណ្តាលមកពីការទិញ ឬបោះផ្សាយទ្រព្យសកម្ម ឬបំណុលនោះ។

*(ii). ការចាត់ថ្នាក់*

ក្រុមហ៊ុនចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋានស្របទៅតាមផ្នែកទី11 ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន។

*(iii). ការឈប់ទទួលស្គាល់*

ក្រុមហ៊ុន ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាពីទ្រព្យសកម្មហិរញ្ញវត្ថុនោះផុតកំណត់ ឬបានទូទាត់ ឬក្រុមហ៊ុន បានផ្ទេរសិទ្ធិក្នុងការទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលរាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិទាំងអស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាម្ចាស់កម្មសិទ្ធិ ហើយក្រុមហ៊ុនមិនរក្សាទុកការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចតាមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតកំណត់។

*(iv). ការកាត់កង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កង និងមានបំណងធ្វើការទូទាត់លើមូលដ្ឋានតម្លៃសុទ្ធ ឬដើម្បីទទួលបានទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

*(v). ការវាស់វែងថ្លៃដើមរំលស់*

ថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនៅពេលទទួលស្គាល់ដំបូង ដកការទូទាត់ប្រាក់ដើម បូក ឬដករំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ពេលទទួលស្គាល់ដំបូង និងចំនួនទឹកប្រាក់ពេលដល់កាលកំណត់ ដកការថយចុះលើអ៊ឹមភែរមិន។

2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

***ឧបករណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

*(vi) ការវាស់វែងតម្លៃទីផ្សារ*

តម្លៃទីផ្សារ ជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារដែលមានអត្ថប្រយោជន៍បំផុត ដែលក្រុមហ៊ុនអាចកំណត់បាននៅកាលបរិច្ឆេទនោះ។ តម្លៃទីផ្សាររបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច។

ក្រុមហ៊ុនវាស់វែងតម្លៃទីផ្សាររបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយ ត្រូវបានចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុលកើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណា នៅក្នុងការកំណត់តម្លៃ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃទីផ្សាររបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ ឧទាហរណ៍ តម្លៃទីផ្សារនៃផលតបស្នងបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើក្រុមហ៊ុនកំណត់ថា តម្លៃទីផ្សារនៅពេលទទួលស្គាល់ដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃទីផ្សារនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬតាមរយៈបច្ចេកទេសវាយតម្លៃ ដោយប្រើប្រាស់តែទិន្នន័យទីផ្សារដែលអាចអង្កេតបាន ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងដំបូងតាមតម្លៃទីផ្សារ ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃទីផ្សារនៅពេលទទួលស្គាល់ដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មក ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើមូលដ្ឋានសមរម្យទៅតាមអាយុកាលរបស់ឧបករណ៍នោះ ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារ ដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃទីផ្សារ នៅចុងការិយបរិច្ឆេទរាយការណ៍ពេលដែលការផ្លាស់ប្តូរបានកើតឡើង។

2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

***ឧបករណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

*(vii).ការកំណត់អត្តសញ្ញាណ និងការវាស់វែងអ៊ីមភែរមិន*

*ភស្តុតាងដែលបញ្ជាក់ថាមានអ៊ីមភែរមិន*

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើមានភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកត់ត្រាតាមថ្លៃដើម ឬថ្លៃដើមរំលស់។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាមានអ៊ីមភែរមិន នៅពេលដែលមានភស្តុតាងបញ្ជាក់ថា មានព្រឹត្តិការណ៍ខាតបង់បានកើតឡើងបន្ទាប់ពីការទទួលស្គាល់ទ្រព្យសកម្មដំបូង ហើយព្រឹត្តិការណ៍ខាតបង់នោះ នាំឱ្យមានផលប៉ះពាល់ទៅលើលំហូរសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្ម ដែលអាចប៉ាន់ស្មានដោយភាពជឿជាក់បាន។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានអ៊ីមភែរមិន រួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការខកខានសង ឬហួសកាលកំណត់សងរបស់អតិថិជន
- ការរៀបចំឡើងវិញនៃឥណទាន ឬបុរេប្រទានដោយក្រុមហ៊ុនលើលក្ខខណ្ឌ ដែលក្រុមហ៊ុនមិនបានពិចារណា
- សូចនាករដែលបញ្ជាក់ថាអតិថិជន ឬអ្នកបោះផ្សាយ ទំនងនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រ ឬ
- ទិន្នន័យដែលអាចអង្កេតបានពាក់ព័ន្ធនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមានក្នុងស្ថានភាពនៃការទូទាត់របស់អតិថិជន ឬអ្នកបោះផ្សាយជាក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងការខកខានសងជាក្រុម។

*ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម*

រាល់ទ្រព្យសកម្មដែលមានសារៈសំខាន់ជាលក្ខណៈទោល ត្រូវបានវាយតម្លៃជាលក្ខណៈទោលសម្រាប់អ៊ីមភែរមិន។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនត្រូវបានរកឃើញថាមានអ៊ីមភែរមិនជាក់លាក់ ត្រូវបានវាយតម្លៃជាក្រុមសម្រាប់អ៊ីមភែរមិនដែលបានកើតឡើង ប៉ុន្តែមិនទាន់ទទួលស្គាល់នៅឡើយ។

## 2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

***ឧបករណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

*(vii).ការកំណត់អត្តសញ្ញាណ និងការវាស់វែងអ៊ីមភែរមិន* (តពីទំព័រមុន)

*ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម* (តពីទំព័រមុន)

សមាសធាតុទោលនៃសំវិធានធនសរុបសម្រាប់អ៊ីមភែរមិន ត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាយតម្លៃអ៊ីមភែរមិនជាលក្ខណៈទោល ហើយត្រូវបានរកឃើញថាមានអ៊ីមភែរមិនទោល និងផ្អែកតាមការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់គណៈគ្រប់គ្រងលើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងថានឹងទទួលបាន។ ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ទាំងនេះ គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃសុទ្ធដែលអាចលក់បានចំពោះទ្រព្យបញ្ចាំណាមួយ។ ទ្រព្យសកម្មដែលមានអ៊ីមភែរមិននីមួយៗ ត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខណៈពិសេសរបស់វា ហើយយុទ្ធសាស្ត្រក្នុងការស្តារឡើងវិញ និងការប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលអាចប្រមូលបានមកវិញ ត្រូវបានអនុម័តដោយឯករាជ្យពីគណៈគ្រប់គ្រង។

សមាសធាតុជាក្រុមនៃសំវិធានធនសរុប ត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមឥណទានមានលក្ខណៈស្រដៀងគ្នា ហើយមិនត្រូវបានចាត់ទុកថាមានសារៈសំខាន់ជាលក្ខណៈទោល និង
- ក្រុមទ្រព្យសកម្មដែលមានសារៈសំខាន់ជាលក្ខណៈទោល ប៉ុន្តែមិនត្រូវបានរកឃើញថាមានអ៊ីមភែរមិនជាលក្ខណៈទោលនោះទេ។

សំវិធានធនជាក្រុម សម្រាប់ក្រុមឥណទានមានលក្ខណៈស្រដៀងគ្នា ត្រូវបានបង្កើតឡើងដោយប្រើវិធីសាស្ត្រគណនា ផ្អែកលើបទពិសោធន៍អត្រាខាតប្រវត្តិសាស្ត្រ។

ក្នុងការវាយតម្លៃសំវិធានធនលើការខាតជាក្រុម គណៈគ្រប់គ្រងបានពិចារណាលើកត្តាមួយចំនួនដូចជា គុណភាពឥណទាន ទំហំផលបត្រ ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ចជាដើម។ ដើម្បីប៉ាន់ស្មានតម្រូវការសំវិធានធន ការសន្មតត្រូវបានធ្វើឡើងដើម្បីកំណត់លក្ខណៈគំរូនៃការខាត និងការកំណត់ទិន្នន័យប៉ារ៉ាម៉ែត្រតាមតម្រូវការ ដោយផ្អែកលើបទពិសោធន៍ខាតប្រវត្តិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសំវិធានធន អាស្រ័យលើការសន្មតគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់សំវិធានធនជាក្រុម។

*ការវាស់វែង*

ការខាតអ៊ីមភែរមិនលើទ្រព្យសកម្ម ដែលបានវាស់វែងតាមថ្លៃដើមរំលស់ ត្រូវបានគណនាដោយភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដែលបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដើមរបស់ទ្រព្យសកម្ម។

## 2. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

*ឧបករណ៍ហិរញ្ញវត្ថុ* (តពីទំព័រមុន)

*(vii).ការកំណត់អត្តសញ្ញាណ និងការវាស់វែងអ៊ីមភែរមិន* (តពីទំព័រមុន)

*ការកត់ត្រាបញ្ច្រាស់មកវិញ និងការលុបចោលអ៊ីមភែរមិន*

ប្រសិនបើក្នុងរយៈពេលបន្ទាប់ ចំនួននៃការខាតអ៊ីមភែរមិន មានការថយចុះ ហើយការថយចុះនោះ អាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីអ៊ីមភែរមិនត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវធ្វើការកត់ត្រាបញ្ច្រាស់មកវិញការខាតអ៊ីមភែរមិន ដែលបានទទួលស្គាល់ពីមុន ដោយផ្ទាល់ ឬដោយធ្វើនិយ័តកម្មគណនីសំវិធានធន។

ការកត់ត្រាបញ្ច្រាស់មកវិញ នឹងមិនត្រូវនាំឱ្យតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (កាត់កងគណនីសំវិធានធន) លើសពីតម្លៃយោងដែលគួរមាននៅពេលអ៊ីមភែរមិន មិនបានទទួលស្គាល់ពីមុននោះទេ។ ក្រុមហ៊ុន ត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ដែលកត់ត្រាបញ្ច្រាស់មកវិញ ក្នុងចំណេញ ឬខាតភ្លាមៗ។

ក្រុមហ៊ុន លុបចោលឥណទានផ្នែកខ្លះ ឬទាំងស្រុង និងសំវិធានធន សម្រាប់ការខាតអ៊ីមភែរមិនដែលពាក់ព័ន្ធ នៅពេលដែលគណៈគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពជាក់លាក់ក្នុងការប្រមូលបានមកវិញ។

*សាច់ប្រាក់ និងសាច់ប្រាក់សមមូល*

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យនៅធនាគារ ប្រាក់បញ្ញើ និងការវិនិយោគងាយស្រួលរយៈពេលខ្លី ដែលមានកាលវសានពេលតម្កល់ដំបូងរយៈពេល 3ខែ ឬតិចជាងនេះ ហើយអាចប្តូរជាសាច់ប្រាក់បានគ្រប់ពេល ដោយមានហានិភ័យតិចតួចលើការផ្លាស់ប្តូរតម្លៃ និងត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងកាតព្វកិច្ចរយៈពេលខ្លីរបស់ខ្លួន។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ*

សមតុល្យនៅធនាគារ ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ប្រាក់តម្កល់តាមបទប្បញ្ញត្តិ*

ប្រាក់តម្កល់តាមបទប្បញ្ញត្តិ សំដៅលើប្រាក់តម្កល់ធានាដើមទុនដែលត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដោយស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងត្រូវបានកំណត់តាមភាគរយជាក់លាក់នៃដើមទុនអប្បបរមា តម្រូវដោយធនាគារជាតិ នៃកម្ពុជា។ ប្រាក់តម្កល់តាមបទប្បញ្ញត្តិមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ដូច្នេះវាមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។

## 2. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (តពីទំព័រមុន)

*ប្រាក់តម្កល់តាមបទប្បញ្ញត្តិ* (តពីទំព័រមុន)

ប្រាក់តម្កល់តាមបទប្បញ្ញត្តិ ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ឥណទានទៅអតិថិជន*

ឥណទានទៅអតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទដែលទូទាត់តាមលក្ខណៈថេរ ឬអាចកំណត់បាន ដែលមិនមែនជាតម្លៃដកស្រង់ពីទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់ភ្លាមៗ ឬនៅពេលឆាប់ៗខាងមុខនោះទេ។

ឥណទានទៅអតិថិជន ត្រូវបានវាស់វែងដំបូងតាមតម្លៃទីផ្សារ បូកចំណាយប្រតិបត្តិការកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ ត្រូវវាស់វែងតាមថ្លៃដើមរំលស់ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។

*ការវិនិយោគលើមូលធន*

ការវិនិយោគលើមូលធន ត្រូវបានទទួលស្គាល់តាមថ្លៃដើម ដកការខាតអ៊ីមភែរមិនបង្គរ។ ចំណូលភាគលាភពីការវិនិយោគលើមូលធន ត្រូវបានទទួលស្គាល់នៅពេលដែលសិទ្ធិរបស់ក្រុមហ៊ុន ក្នុងការទទួលបានការទូទាត់ត្រូវបានបង្កើតឡើង និងកត់ត្រានៅក្នុងចំណូលប្រតិបត្តិការផ្សេងៗ។

*ទ្រព្យសកម្មផ្សេងៗ*

ទ្រព្យសកម្មផ្សេងៗទៀត ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

*ទ្រព្យ និងបរិក្ខារ*

ធាតុនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតអ៊ីមភែរមិនបង្គរប្រសិនបើមាន។ នៅពេលដែលធាតុមួយនៃទ្រព្យ និងបរិក្ខារ រួមមានផ្នែកច្រើនដែលមានអាយុកាលប្រើប្រាស់ខុសៗគ្នា ផ្នែកទាំងនោះត្រូវបានចាត់ទុកជាធាតុផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ។

រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ ឬខាតលើមូលដ្ឋានរំលស់ថេរតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារនីមួយៗ ដូចខាងក្រោម៖

| | **អាយុកាលប្រើប្រាស់** |
|---|---|
| ការកែលម្អទ្រព្យភតិសន្យា | 2 ទៅ 10ឆ្នាំ |
| បរិក្ខារការិយាល័យ | 4ឆ្នាំ |
| កុំព្យូទ័រ និងបរិក្ខារព័ត៌មានវិទ្យា | 4ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | 4ឆ្នាំ |
| យានយន្ត | 4ឆ្នាំ |

ការសាងសង់កំពុងដំណើរការ មិនត្រូវបានរំលស់រហូតដល់ពេលដែលទ្រព្យសកម្មនោះ ត្រូវបានសាងសង់រួច និងដាក់ឱ្យប្រើប្រាស់ក្នុងប្រតិបត្តិការ។

2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

*ទ្រព្យ និងបរិក្ខារ* (តពីទំព័រមុន)

ចំណាយបន្តបន្ទាប់ដែលពាក់ព័ន្ធទៅនឹងធាតុណាមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃធាតុនោះ នៅពេលដែលវាអាចផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុន លើសពីស្តង់ដាប្រើប្រាស់ដែលបានវាយតម្លៃដំបូង។ រាល់ចំណាយបន្តបន្ទាប់ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

ចំណេញ ឬខាតពីការឈប់ប្រើប្រាស់ ឬការលក់ធាតុនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងការប៉ាន់ស្មាននៃសាច់ប្រាក់សុទ្ធទទួលបានពីការលក់ និងតម្លៃយោងនៃធាតុនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត នៅពេលដែលឈប់ប្រើប្រាស់ ឬលក់។

ទ្រព្យ និងបរិក្ខារ ដែលបានរំលស់អស់ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ពេលដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ ឬលុបចោល។

*ទ្រព្យសកម្មអរូបី*

ទ្រព្យសកម្មអរូបី ដែលរួមមានកុំព្យូទ័រសូហ្វវែរ ត្រូវបានវាស់វែងតាមថ្លៃដើម ដករំលស់បង្គរ និងការខាតអ៊ីមភែរមិនបង្គរ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបី ត្រូវបានរំលស់តាមវិធីសាស្ត្ររំលស់ថេររយៈពេល 5ឆ្នាំ។

ថ្លៃដើមដែលបានកើតឡើងក្នុងការរៀបចំផែនការ ឬវាយតម្លៃសំណើរសូហ្វវែរ ឬក្នុងការថែទាំប្រព័ន្ធបន្ទាប់ពីដាក់ឱ្យដំណើរការ មិនត្រូវបានទទួលស្គាល់ជាផ្នែកនៃថ្លៃដើមទេ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃនៅសល់ ត្រូវពិនិត្យឡើងវិញ និងនិយ័តកម្មនៅរៀងរាល់ការិយបរិច្ឆេទរាយការណ៍ ប្រសិនបើវាសមស្រប។

*អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (ក្រៅពីពន្ធពន្យារជាទ្រព្យសកម្ម) ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសូចនាករណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានអ៊ីមភែរមិន។ ប្រសិនបើមានសូចនាករនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃទីផ្សារ ដកចំណាយដើម្បីលក់។ ក្នុងការវាយតម្លៃ តម្លៃប្រើប្រាស់ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារមកតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់មុនគិតពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃនៃពេលវេលា និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការធ្វើតេស្តលើអ៊ីមភែរមិន ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មផ្សេងៗ ឬក្រុមនៃទ្រព្យសកម្ម ("ឯកតាបង្កើតសាច់ប្រាក់")។

2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

*អ៊ីមភែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ* (តពីទំព័រមុន)

ការខាតអ៊ីមភែរមិន ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ លើសពីតម្លៃដែលអាចប្រមូលបានមកវិញ។ ការខាតអ៊ីមភែរមិនត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

*ដើមទុន និងបុព្វលាភភាគហ៊ុន*

ចំណាយបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការបោះផ្សាយឧបករណ៍មូលធន ត្រូវបានដកចេញពីការវាស់វែងដំបូងនៃឧបករណ៍មូលធន។ ចំនួនទឹកប្រាក់ដែលទទួលបានលើសពីតម្លៃចារឹកត្រូវបានកត់ត្រាជាបុព្វលាភភាគហ៊ុន។

*ទុនបម្រុងតាមបទប្បញ្ញត្តិ*

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃសំវិធានធន រវាងអ៊ីមភែរមិននៃឥណទានដោយអនុលោមតាម CIFRS for SMEs និងសំវិធានធនតាមបទប្បញ្ញត្តិអនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំលេខ ធ7-018-001 ស.រ.ច.ណ ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

យោងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា រាល់ឥណទានទៅអតិថិជន ត្រូវចាត់ថ្នាក់តាមសមត្ថភាពសងរបស់អ្នកខ្ចី និងចំនួនថ្ងៃដែលហួសកាលកំណត់សងដូចខាងក្រោម៖

| **ចំណាត់ថ្នាក់** | **ចំនួនថ្ងៃដែលហួសកាលកំណត់សង** | **សំវិធានធន** |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាង ឬស្មើមួយឆ្នាំ)៖** | | |
| ធម្មតា/ស្តង់ដា | <15 ថ្ងៃ | 1% |
| ឃ្លាំមើល | 15 ថ្ងៃ ដល់ 30 ថ្ងៃ | 3% |
| ក្រោមស្តង់ដា | 31 ថ្ងៃ ដល់ 60 ថ្ងៃ | 20% |
| ជាប់សង្ស័យ | 61 ថ្ងៃ ដល់ 90 ថ្ងៃ | 50% |
| បាត់បង់ | ⩾ 91 ថ្ងៃ | 100% |
| **ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)៖** | | |
| ធម្មតា/ស្តង់ដា | < 30 ថ្ងៃ | 1% |
| ឃ្លាំមើល | ⩾ 30 ថ្ងៃ ដល់ 89 ថ្ងៃ | 3% |
| ក្រោមស្តង់ដា | ⩾ 90 ថ្ងៃ ដល់ 179 ថ្ងៃ | 20% |
| ជាប់សង្ស័យ | ⩾ 180 ថ្ងៃ ដល់ 359 ថ្ងៃ | 50% |
| បាត់បង់ | 359 ថ្ងៃ ឬច្រើនជាងនេះ | 100% |

2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

***ទុនបម្រុងតាមបទប្បញ្ញត្តិ*** (តពីទំព័រមុន)

ដោយអនុលោមតាមប្រកាស ក្រុមហ៊ុនត្រូវប្រៀបធៀបសំវិធានធនដែលគណនាតាមការតម្រូវខាងលើ ជាមួយនឹងសំវិធានធនដែលគណនាតាម CIFRS for SMEs ៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិតិចជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនគណនាតាម CIFRS for SMEs ឬ

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិច្រើនជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនគណនាតាម CIFRS for SMEs និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងគណនីមូលធន។

ទុនបម្រុងតាមបទប្បញ្ញត្តិ មិនត្រូវបានបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ របស់ក្រុមហ៊ុនឡើយ។

***ប្រាក់កម្ចី និងបំណុលផ្សេងៗ***

ប្រាក់កម្ចី និងបំណុលផ្សេងៗ ត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

***សំវិធានធន***

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចដោយប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ដែលកន្លងផុតទៅ ហើយវាអាចតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការទូទាត់កាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់ជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយធ្វើអប្បហារលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត ដោយប្រើអត្រាមុនគិតពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃនៃពេលវេលា និងហានិភ័យជាក់លាក់លើបំណុលទាំងនោះ។ តម្លៃនៃអប្បហារនេះ ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

***អត្ថប្រយោជន៍និយោជិត***

*(i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់។ បំណុលត្រូវបានទទួលស្គាល់សម្រាប់ចំនួនទឹកប្រាក់ដែលរំពឹងទុកថានឹងត្រូវទូទាត់ ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចដោយប្រយោលក្នុងការទូទាត់ចំនួនទឹកប្រាក់ដែលជាលទ្ធផលនៃការងារ ដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

## 2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

***អត្ថប្រយោជន៍និយោជិត*** (តពីទំព័រមុន)

*(ii) ផែនការវិភាគទានដែលបានកំណត់ - ប្រាក់សោធន*

កាតព្វកិច្ចសម្រាប់ការរួមចំណែកចំពោះផែនការវិភាគទានដែលបានកំណត់ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ និងត្រូវបានទទួលស្គាល់ជាចំណាយបុគ្គលិក នៅក្នុងចំណេញ ឬខាត។ ការរួមចំណែកដែលបានបង់មុន ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម រហូតដល់សាច់ប្រាក់ត្រូវបានបង្វិលមកវិញ ឬមានការដកចេញពីការទូទាត់នាពេលអនាគត។

*(iii) អត្ថប្រយោជន៍និយោជិតរយៈពេលវែង*

កាតព្វកិច្ចសុទ្ធរបស់ក្រុមហ៊ុនចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង ជាចំណាយលើអត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបាន ពីការបំពេញការងារក្នុងការិយបរិច្ឆេទបច្ចុប្បន្ន និងកន្លងផុតទៅ រួមទាំងប្រាក់បំណាច់អតីតភាពការងារ។ អត្ថប្រយោជន៍និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន។ ការវាស់វែងឡើងវិញ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

*ការប្រាក់*

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព គឺជាវិធីសាស្ត្រនៃការគណនាថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ និងបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់ទៅតាមរយៈពេលដែលពាក់ព័ន្ធ។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់នាពេលអនាគតដែលរំពឹងថានឹងទូទាត់ និងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬរយៈពេលខ្លីជាង ប្រសិនបើសមស្រប) ទៅតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុនោះ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតឥណទានរំពឹងទុកនាពេលអនាគតនោះទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬបានទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

*កម្រៃ និងចំណាយជើងសារ*

កម្រៃ និងចំណូល និងចំណាយជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

កម្រៃ និងចំណូលជើងសារផ្សេងៗ ត្រូវបានទទួលស្គាល់នៅពេលសេវាកម្មពាក់ព័ន្ធត្រូវបានបំពេញ។ ប្រសិនបើកិច្ចសន្យាឥណទាន មិនត្រូវបានរំពឹងថានឹងមានលទ្ធផលក្នុងការដកឥណទាន នោះកម្រៃពីកិច្ចសន្យាឥណទានពាក់ព័ន្ធ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមរយៈពេលនៃកិច្ចសន្យា។

កម្រៃ និងចំណាយជើងសារផ្សេងៗ ពាក់ព័ន្ធជាចម្បងលើកម្រៃប្រតិបត្តិការ និងសេវាកម្ម ត្រូវបានចំណាយ នៅពេលសេវាកម្មត្រូវបានទទួល។

*ភតិសន្យា*

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌនៃភតិសន្យា ផ្ទេររាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យទាំងអស់នៃភតិសន្យាទៅកាន់ក្រុមហ៊ុន។ ភតិសន្យាផ្សេងៗទៀត ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។

ការទូទាត់ភតិសន្យាដែលមានទម្រង់ជាភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតតាមមូលដ្ឋានថេរទៅតាមរយៈពេលនៃការជួល។ ការលើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃចំណាយភតិសន្យាសរុបក្នុងរយៈពេលនៃការជួល។

*ពន្ធលើប្រាក់ចំណូល*

ពន្ធលើប្រាក់ចំណូល រួមមានពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងពន្ធពន្យារ។ វាត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត លើកលែងក្នុងករណីដែលវាពាក់ព័ន្ធទៅនឹងធាតុណាដែលទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬនៅក្នុងរបាយការណ៍លទ្ធផលពេញលេញផ្សេងៗ។

*(i). ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ*

ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ ឬត្រូវទទួលលើប្រាក់ចំណូល ឬខាតជាប់ពន្ធប្រចាំឆ្នាំ និងនិយ័តកម្មលើពន្ធដែលត្រូវបង់ ឬត្រូវទទួលដែលទាក់ទងទៅនឹងការិយបរិច្ឆេទមុនៗ។ ចំនួននៃពន្ធដែលត្រូវបង់ ឬត្រូវទទួលប្រចាំឆ្នាំ គឺជាការប៉ាន់ស្មានដ៏ល្អបំផុតនៃចំនួនពន្ធដែលរំពឹងថានឹងត្រូវបង់ ឬត្រូវទទួល ដែលឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់ទាក់ទងនឹងពន្ធលើប្រាក់ចំណូល ប្រសិនបើមាន។ វាត្រូវបានវាស់វែងដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

*ពន្ធលើប្រាក់ចំណូល* (តពីទំព័រមុន)

*(ii). ពន្ធពន្យារ*

ពន្ធពន្យារ ត្រូវបានទទួលស្គាល់លើភាពលម្អៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់គោលបំណងពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់លើខាតតាមពន្ធមិនបានប្រើប្រាស់ ឥណទានពន្ធមិនបានប្រើប្រាស់ និងភាពលម្អៀងជាបណ្តោះអាសន្នដែលអាចកាត់កងបាន ក្នុងករណីដែលអាចទៅរួចដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងមានគ្រប់គ្រាន់ ដើម្បីអាចប្រើប្រាស់បាន។ ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ត្រូវបានកំណត់ដោយផ្អែកលើផែនការអាជីវកម្មរបស់ក្រុមហ៊ុន និងការកត់ត្រាបញ្ច្រាស់មកវិញនៃភាពខុសគ្នាបណ្តោះអាសន្ន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវបានកាត់បន្ថយក្នុងករណីដែលវាមិនអាចទៅរួច ដែលអត្ថប្រយោជន៍ពន្ធពាក់ព័ន្ធអាចនឹងប្រើប្រាស់បាន។

ពន្ធពន្យារជាទ្រព្យសកម្មមិនបានទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់តែក្នុងករណីដែលអាចទៅរួចដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងមានគ្រប់គ្រាន់ ដើម្បីអាចប្រើប្រាស់បាន។

ពន្ធពន្យារត្រូវបានកំណត់ដោយប្រើអត្រាពន្ធ ដែលរំពឹងថានឹងប្រើលើភាពលម្អៀងជាបណ្តោះអាសន្នពេលដែលកត់ត្រាបញ្ច្រាស់មកវិញ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងពីលទ្ធផលពន្ធដែលនឹងកើតឡើងតាមរបៀបដែលក្រុមហ៊ុនរំពឹងថានឹងទទួលបានមកវិញ ឬកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងគ្នាបានក្នុងករណីមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការកាត់កងបំណុលពន្ធ និងទ្រព្យសកម្ម ហើយមានការទាក់ទងនឹងពន្ធលើប្រាក់ចំណូលដែលបានកំណត់ដោយអាជ្ញាធរពន្ធតែមួយ លើស្ថាប័នតែមួយ ឬលើស្ថាប័នពន្ធផ្សេងគ្នា ប៉ុន្តែពួកគេមានបំណងទូទាត់បំណុលពន្ធ និងទ្រព្យសកម្មលើមូលដ្ឋានសុទ្ធ ឬពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលរបស់ពួកគេនឹងត្រូវបានទទួលស្គាល់ក្នុងពេលដំណាលគ្នា។

## 2. **សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ** (តពីទំព័រមុន)

*ស្តង់ដា និងវិសោធនកម្មដែលបានចេញផ្សាយ តែមិនទាន់មានប្រសិទ្ធិភាព*

នៅថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2025 ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិបានចេញផ្សាយកំណែប្រែលើកទីបី នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់សហគ្រាសធុនតូច និងមធ្យម ("IFRS for SMEs" ឬ "ស្តង់ដា") ដើម្បីឆ្លុះបញ្ចាំងពីការបង្កើនភាពស្របគ្នាជាមួយស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("IFRS") ស្របពេលដែលនៅតែបន្តរក្សាភាពសាមញ្ញក្នុងគោលដៅ ដើម្បីធានាថាវាតែមានភាពពាក់ព័ន្ធ និងសាមញ្ញ ដោយផ្អែកលើតម្រូវការរបស់អ្នកប្រើប្រាស់ និងការពិចារណាអំពីអត្ថប្រយោជន៍ និងចំណាយ។ និយ័តករគណនេយ្យ និងសវនកម្មបានចេញសេចក្តីជូនដំណឹងជាផ្លូវការលេខ 008/25 ចុះថ្ងៃទី13 ខែមីនា ឆ្នាំ2025 ទាក់ទងនឹងការបោះពុម្ពលើកទីបីនៃ IFRS for SMEs ដែលមានសុពលភាពចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2027 ជាមួយនឹងការលើកទឹកចិត្តសម្រាប់ការអនុវត្តមុន។ បច្ចុប្បន្ន ក្រុមហ៊ុនកំពុងធ្វើការកំណត់ផលប៉ះពាល់ទាំងអស់នៃការធ្វើវិសោធនកម្ម ដែលនឹងមានទៅលើរបាយការណ៍ហិរញ្ញវត្ថុ។

## 3. **ការវិនិច្ឆ័យ និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ**

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គណៈគ្រប់គ្រងបាន ធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មត ដែលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួនទឹកប្រាក់នៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មាន ត្រូវបានទទួលស្គាល់ជាមុនសម្រាប់ពេលអនាគត។

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ជាលទ្ធផលបណ្តាលឱ្យមាននិយតកម្មជាសារវន្ត នៅក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ត្រូវបានបង្ហាញនៅខាងក្រោមទាក់ទងនឹងអ៊ីមភែរមិននៃឧបករណ៍ហិរញ្ញវត្ថុ និងក្នុងកំណត់សម្គាល់លេខ 2 *(ឧបករណ៍ហិរញ្ញវត្ថុ – ការកំណត់អត្តសញ្ញាណ និងការវាស់វែងអ៊ីមភែរមិន)*។

## 4. **សាច់ប្រាក់ក្នុងដៃ**

| | *2025* | | *2024* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ដុល្លារអាមេរិក | 2,700 | 10,835 | 2,531 | 10,188 |
| ខ្មែររៀល | 1,486 | 5,963 | 628 | 2,528 |
| | **4,186** | **16,798** | **3,159** | **12,716** |

## 5. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ

| | 2025 | | 2024 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| គណនីចរន្ត | 20,032 | 80,388 | 4,662 | 18,765 |
| គណនីសន្សំ | 795,984 | 3,194,284 | 908,621 | 3,657,199 |
| ប្រាក់បញ្ញើមានកាលកំណត់ | 498,585 | 2,000,822 | - | - |
| | **1,314,601** | **5,275,494** | **913,283** | **3,675,964** |

សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវបានវិភាគបន្ថែមដូចខាងក្រោម៖

| | 2025 | | 2024 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| **ក. តាមកាលវសាន៖** | | | | |
| រយៈពេល 1ខែ | 816,016 | 3,274,672 | 913,283 | 3,675,964 |
| ពី 2 ទៅ 3 ខែ | 498,585 | 2,000,822 | - | - |
| | **1,314,601** | **5,275,494** | **913,283** | **3,675,964** |

**ខ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖**

អត្រាការប្រាក់ប្រចាំឆ្នាំដែលអនុវត្តចំពោះសមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | *2025* | *2024* |
|---|---|---|
| គណនីចរន្ត | 0.00% - 0.50% | គ្មាន |
| គណនីសន្សំ | 0.00% - 2.00% | 2.00% |
| ប្រាក់បញ្ញើមានកាលកំណត់ | 2.50% | - |

## 6. សមតុល្យនៅធនាគារជាតិ នៃកម្ពុជា

| | *2025* | | *2024* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| គណនីចរន្ត | 20,325 | 81,564 | 2,239 | 9,012 |
| ប្រាក់តម្កល់ធានាដើមទុន (*) | 254,765 | 1,022,372 | 254,765 | 1,025,429 |
| | **275,090** | **1,103,936** | **257,004** | **1,034,441** |

(*) ដោយអនុលោមតាមប្រកាសលេខ ធ7-00-006 ប្រ.ក ចុះថ្ងៃទី11 ខែមករា ឆ្នាំ2000 និងប្រកាសលេខ ធ7-06-209 ប្រ.ក ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2006 ស្តីពីការផ្តល់អាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនតម្រូវឱ្យរក្សាទុកប្រាក់តម្កល់ធានាដើមទុនស្មើនឹង 5% នៃដើមទុនចុះបញ្ជីនៅធនាគារជាតិ នៃកម្ពុជា។ ប្រាក់តម្កល់នេះ មិនអាចយកមកប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនបានឡើយ ប៉ុន្តែក្រុមហ៊ុនអាចដកមកវិញបាន នៅពេលដែលក្រុមហ៊ុនសម្រេចចិត្តឈប់ធ្វើអាជីវកម្ម នៅក្នុងប្រទេសកម្ពុជាដោយស្ម័គ្រចិត្ត។

ប្រាក់តម្កល់ធានាដើមទុនទទួលបានអត្រាការប្រាក់ពី 1.03% - 1.06% (ឆ្នាំ2024៖ 1.29% - 1.31%) ក្នុងមួយឆ្នាំ។ គណនីចរន្តនៅធនាគារជាតិ នៃកម្ពុជា មិនមានការប្រាក់ទេ។

## 7. ឥណទានទៅអតិថិជនសុទ្ធ

| | *2025* | | *2024* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ឥណទានឯកត្តជន | 9,310,599 | 37,363,434 | 8,324,033 | 33,504,233 |
| ឥណទានជាក្រុម | 116 | 466 | 28,227 | 113,614 |
| ឥណទានទៅបុគ្គលិក | 149,334 | 599,277 | 311,648 | 1,254,383 |
| ឥណទានទៅសហគ្រាសធុនតូច-មធ្យម | 11,463,388 | 46,002,575 | 17,532,996 | 70,570,308 |
| **ឥណទានទៅអតិថិជនដុល** | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |
| ដក៖ សំវិធានធនលើខាតអ៊ីមភែរមិន | (1,546,651) | (6,206,710) | (2,354,869) | (9,478,348) |
| | **19,376,786** | **77,759,042** | **23,842,035** | **95,964,190** |

## 7. **ឥណទានទៅអតិថិជនសុទ្ធ** (តពីទំព័រមុន)

បម្រែបម្រួលសំវិធានធនលើខាតអ៊ីមភែរមិនក្នុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | *ការវាយតម្លៃ ទោល* | *ការវាយតម្លៃ ជាក្រុម* | *សរុប* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| 2025 | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | 1,938,479 | 416,390 | 2,354,869 | 9,478,348 |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | 196,796 | 67,052 | 263,848 | 1,058,294 |
| លុបចោលក្នុងការិយបរិច្ឆេទ | (972,234) | (99,832) | (1,072,066) | (4,300,057) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | (29,875) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025** | **1,163,041** | **383,610** | **1,546,651** | **6,206,710** |

| | *ការវាយតម្លៃ ទោល* | *ការវាយតម្លៃ ជាក្រុម* | *សរុប* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| 2024 | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | 737,762 | 1,130,277 | 1,868,039 | 7,630,939 |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | 2,633,674 | 42,712 | 2,676,386 | 10,895,567 |
| លុបចោលក្នុងការិយបរិច្ឆេទ | (1,432,957) | (756,599) | (2,189,556) | (8,913,682) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | (134,476) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | **1,938,479** | **416,390** | **2,354,869** | **9,478,348** |

ខាតអ៊ីមភែរមិនសុទ្ធក្នុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | *2025* | | *2024* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2) (បានចាត់ថ្នាក់ឡើងវិញ - កំណត់សម្គាល់លេខ 31)* |
| ឥណទានទៅអតិថិជន | 263,848 | 1,058,294 | 2,676,386 | 10,895,567 |
| ការប្រមូលបានមកវិញពីឥណទានដែលបានលុបចោល | (159,890) | (641,318) | (54,512) | (221,918) |
| | **103,958** | **416,976** | **2,621,874** | **10,673,649** |

## 7. **ឥណទានទៅអតិថិជនសុទ្ធ** (តពីទំព័រមុន)

ឥណទានទៅអតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖

| | | 2025 | | 2024 | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ក. | **តាមកាលវសាន៖** | | | | |
| | ក្នុងរយៈពេល 3ខែ | 306,765 | 1,231,048 | 219,313 | 882,735 |
| | ពី 4 ទៅ 6ខែ | 374,204 | 1,501,681 | 333,989 | 1,344,306 |
| | ពី 7 ទៅ 12ខែ | 1,344,711 | 5,396,325 | 1,460,747 | 5,879,507 |
| | លើសពី 12ខែ | 18,897,757 | 75,836,698 | 24,182,855 | 97,335,990 |
| | | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |
| ខ. | **តាមរូបិយប័ណ្ណ៖** | | | | |
| | ដុល្លារអាមេរិក | 17,175,719 | 68,926,158 | 22,906,034 | 92,196,786 |
| | ខ្មែររៀល | 3,747,718 | 15,039,594 | 3,290,870 | 13,245,752 |
| | | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |
| គ. | **តាមវិស័យសេដ្ឋកិច្ច៖** | | | | |
| | សំណង់ | 8,823,757 | 35,409,737 | 11,113,941 | 44,733,613 |
| | កសិកម្ម | 3,057,712 | 12,270,598 | 4,181,954 | 16,832,365 |
| | ការជួញដូរ និងពាណិជ្ជកម្ម | 2,393,164 | 9,603,767 | 3,321,536 | 13,369,182 |
| | សេវាកម្ម | 1,104,820 | 4,433,643 | 1,404,165 | 5,651,764 |
| | លក្ខណៈគ្រួសារ | 771,901 | 3,097,639 | 945,758 | 3,806,676 |
| | ការដឹកជញ្ជូន | 634,490 | 2,546,208 | 1,098,333 | 4,420,790 |
| | ឥណទានទៅបុគ្គលិក | 149,335 | 599,281 | 311,647 | 1,254,379 |
| | ផ្សេងៗ | 3,988,258 | 16,004,879 | 3,819,570 | 15,373,769 |
| | | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |
| ឃ. | **តាមនិវាសនដ្ឋាន៖** | | | | |
| | និវាសនជន | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |
| ង. | **តាមទំនាក់ទំនង៖** | | | | |
| | អតិថិជនខាងក្រៅ | 20,774,102 | 83,366,471 | 25,885,257 | 104,188,159 |
| | ឥណទានទៅបុគ្គលិក | 149,335 | 599,281 | 311,647 | 1,254,379 |
| | | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |
| ច. | **តាមមានការធានា/មិនមានការធានា៖** | | | | |
| | មានការធានា | 14,855,473 | 59,615,012 | 22,395,793 | 90,143,066 |
| | មិនមានការធានា | 6,067,964 | 24,350,740 | 3,801,111 | 15,299,472 |
| | | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |

## 7. ឥណទានទៅអតិថិជនសុទ្ធ (តពីទំព័រមុន)

ឥណទានទៅអតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖ (តពីទំព័រមុន)

ឥណទានមានការធានា ត្រូវបានបញ្ចាំដោយប្លង់រឹង និងទន់។ ប្លង់ទន់ មិនត្រូវបានចេញដោយមន្ទីរសុរិយោដីទេ ប៉ុន្តែត្រូវបានបញ្ជាក់ដោយមេភូមិ ដែលអចលនទ្រព្យស្ថិតនៅ។ ឥណទានមិនមានការធានា សំដៅលើឥណទានមិនមានទ្រព្យបញ្ចាំ។

| | 2025 | | 2024 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| **ឆ. តាមហួសកាលកំណត់សង៖** | | | | |
| ឥណទានមានរយៈពេល 1ឆ្នាំ ឬតិចជាង | | | | |
| តិចជាង 15ថ្ងៃ | 285,940 | 1,147,476 | 230,423 | 927,453 |
| ពី 15ថ្ងៃ ទៅ 30ថ្ងៃ | 7,779 | 31,217 | 6,739 | 27,124 |
| ពី 31ថ្ងៃ ទៅ 60ថ្ងៃ | 2,509 | 10,069 | - | - |
| ពី 61ថ្ងៃ ទៅ 90ថ្ងៃ | 1,167 | 4,683 | 473 | 1,904 |
| ≥ 91ថ្ងៃ | 7,967 | 31,972 | 1,210 | 4,870 |
| | **305,362** | **1,225,417** | **238,845** | **961,351** |
| ឥណទានមានរយៈពេលលើសពី 1ឆ្នាំ | | | | |
| តិចជាង 30ថ្ងៃ | 18,870,042 | 75,725,478 | 23,257,743 | 93,612,416 |
| ≥ 30ថ្ងៃ ទៅ 89ថ្ងៃ | 475,726 | 1,909,088 | 637,156 | 2,564,553 |
| ≥ 90ថ្ងៃ ទៅ 179ថ្ងៃ | 342,343 | 1,373,822 | 683,365 | 2,750,544 |
| ≥ 180ថ្ងៃ ទៅ 359ថ្ងៃ | 401,437 | 1,610,967 | 735,669 | 2,961,068 |
| លើសពី 359ថ្ងៃ | 528,527 | 2,120,980 | 644,126 | 2,592,606 |
| | **20,618,075** | **82,740,335** | **25,958,059** | **104,481,187** |
| | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |
| **ជ. តាមការអនុគ្រោះ៖** | | | | |
| បានរៀបចំឡើងវិញ (*) | 3,429,086 | 13,760,922 | 2,656,521 | 10,692,497 |
| មិនបានរៀបចំឡើងវិញ | 17,494,351 | 70,204,830 | 23,540,383 | 94,750,041 |
| | **20,923,437** | **83,965,752** | **26,196,904** | **105,442,538** |

(*) ឥណទានរៀបចំឡើងវិញ″ គឺជាឥណទានដែលលក្ខខណ្ឌនៃកិច្ចសន្យាដើមត្រូវបានកែប្រែ ដើម្បីផ្តល់នូវលក្ខខណ្ឌអនុគ្រោះ សម្រាប់អ្នកខ្ចីក្នុងហេតុផលសមស្របទាក់ទងនឹងភាពប្រាកដប្រជានៃវិបត្តិហិរញ្ញវត្ថុបណ្តោះអាសន្ន។

## 7. ឥណទានទៅអតិថិជនសុទ្ធ (តពីទំព័រមុន)

ឥណទានទៅអតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖ (តពីទំព័រមុន)

**ឈ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖**

| | *2025* | *2024* |
|---|---|---|
| ឥណទានឯកត្តជន | 12.00% - 18.00% | 14.00% - 18.00% |
| ឥណទានជាក្រុម | 15.60% - 18.00% | 16.00% - 18.00% |
| ឥណទានទៅបុគ្គលិក | 12.00% - 15.60% | 12.00% - 16.00% |
| ឥណទានទៅសហគ្រាសធុនតូច-មធ្យម | 13.20% - 18.00% | 13.00% - 18.00% |

## 8. ការវិនិយោគលើមូលធន

ការវិនិយោគនេះសំដៅលើ ថ្លៃដើមនៃការវិនិយោគលើមូលធននៅក្នុងក្រុមហ៊ុន ក្រេឌីត ប្យួរ៉ូ ហូលឌីង (ខេមបូឌា) ម.ក ("CBH") តាមរយៈសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ CBH គឺជាភាគទុនិកមួយរបស់ក្រេឌីត ប្យួរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដែលជាក្រុមហ៊ុនធ្វើប្រតិបត្តិការជាអ្នកផ្តល់ព័ត៌មាន ឧបករណ៍វិភាគ និងសេវាកម្មរបាយការណ៍ឥណទានឈានមុខគេ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## 9. ទ្រព្យសកម្មផ្សេងៗ

| | *2025* | | *2024* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ឥណទានពន្ធលើប្រាក់ចំណូល *(កំណត់សម្គាល់លេខ 18គ)* | 159,847 | 641,466 | 114,842 | 462,239 |
| ចំណាយបង់មុន | 34,230 | 137,365 | 24,033 | 96,733 |
| ប្រាក់កក់មិនអាចបង្វិលមកវិញបាន | 26,359 | 105,779 | 28,416 | 114,374 |
| ផ្សេងៗ | 3,013 | 12,091 | 14,786 | 59,515 |
| | **223,449** | **896,701** | **182,077** | **732,861** |

## 10. ទ្រព្យ និងបរិក្ខារ

| | *ការកែលម្អទ្រព្យភតិសន្យា* | *បរិក្ខារការិយាល័យ* | *កុំព្យូទ័រ និងបរិក្ខារព័ត៌មានវិទ្យា* | *គ្រឿងសង្ហារឹម និងគ្រឿងបំពាក់* | *យានយន្ត* | *ការសាងសង់កំពុងដំណើរការ* | *សរុប* | |
|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **2025** | | | | | | | | |
| **ថ្លៃដើម** | | | | | | | | |
| នាថ្ងៃទី1 ខែមករា | 40,782 | 42,827 | 228,243 | 41,307 | 92,832 | 80,380 | 526,371 | 2,118,643 |
| ការទិញបន្ថែម | 440 | - | 12,303 | - | - | - | 12,743 | 51,112 |
| ការលក់ | 80,380 | - | - | - | - | (80,380) | - | - |
| ការផ្ទេរ | (24,571) | (21,447) | (86,107) | (12,017) | (750) | - | (144,892) | (581,162) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | (6,580) |
| **នាថ្ងៃទី31 ខែធ្នូ** | **97,031** | **21,380** | **154,439** | **29,290** | **92,082** | **-** | **394,222** | **1,582,013** |
| **ដកៈ រំលស់បង្គរ** | | | | | | | | |
| នាថ្ងៃទី1 ខែមករា | 38,555 | 39,508 | 185,333 | 37,346 | 92,832 | - | 393,574 | 1,584,135 |
| រំលស់ក្នុងការិយបរិច្ឆេទ *(កំណត់សម្គាល់លេខ 24)* | 15,313 | 1,050 | 27,369 | 3,172 | - | - | 46,904 | 188,131 |
| ការលក់ | (24,571) | (21,158) | (85,487) | (11,917) | (750) | - | (143,883) | (577,115) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | (4,915) |
| **នាថ្ងៃទី31 ខែធ្នូ** | **29,297** | **19,400** | **127,215** | **28,601** | **92,082** | **-** | **296,595** | **1,190,236** |
| **តម្លៃពិតគណនេយ្យ** | | | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ** | **67,734** | **1,980** | **27,224** | **689** | **-** | **-** | **97,627** | **391,777** |

## 10. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

| | *ការកែលម្អទ្រព្យភតិសន្យា* | *បរិក្ខារការិយាល័យ* | *កុំព្យូទ័រ និងបរិក្ខារព័ត៌មានវិទ្យា* | *គ្រឿងសង្ហារឹម និងគ្រឿងបំពាក់* | *យានយន្ត* | *ការសាងសង់កំពុងដំណើរការ* | *សរុប* | |
|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| **2024** | | | | | | | | |
| **ថ្លៃដើម** | | | | | | | | |
| នាថ្ងៃទី1 ខែមករា | 41,690 | 47,484 | 217,678 | 41,307 | 92,832 | - | 440,991 | 1,801,448 |
| ការទិញបន្ថែម | - | 2,145 | 10,565 | - | - | 80,380 | 93,090 | 378,969 |
| ការលក់ | (908) | (6,802) | - | - | - | - | (7,710) | (31,387) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | (30,387) |
| **នាថ្ងៃទី31 ខែធ្នូ** | **40,782** | **42,827** | **228,243** | **41,307** | **92,832** | **80,380** | **526,371** | **2,118,643** |
| **ដកៈ រំលស់បង្គរ** | | | | | | | | |
| នាថ្ងៃទី1 ខែមករា | 37,118 | 45,194 | 147,099 | 33,450 | 92,832 | - | 355,693 | 1,453,006 |
| រំលស់ក្នុងការិយបរិច្ឆេទ *(កំណត់សម្គាល់លេខ 24)* | 2,345 | 1,116 | 38,234 | 3,896 | - | - | 45,591 | 185,601 |
| ការលក់ | (908) | (6,802) | - | - | - | - | (7,710) | (31,387) |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | - | - | - | - | (23,085) |
| **នាថ្ងៃទី31 ខែធ្នូ** | **38,555** | **39,508** | **185,333** | **37,346** | **92,832** | **-** | **393,574** | **1,584,135** |
| **តម្លៃពិតគណនេយ្យ** | | | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ** | **2,227** | **3,319** | **42,910** | **3,961** | **-** | **80,380** | **132,797** | **534,508** |

## 11. ទ្រព្យសកម្មអរូបី

| | *កុំព្យូទ័រសូហ្វវែរ* | |
|---|---|---|
| | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **2025** | | |
| **ថ្លៃដើម** | | |
| នាថ្ងៃទី1 ខែមករា | 80,767 | 325,087 |
| ការទិញបន្ថែម | 11,299 | 45,320 |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | (946) |
| **នាថ្ងៃទី31 ខែធ្នូ** | **92,066** | **369,461** |
| **ដកៈ រំលស់បង្គរ** | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | 66,682 | 268,395 |
| រំលស់ក្នុងការិយបរិច្ឆេទ *(កំណត់សម្គាល់លេខ 24)* | 6,046 | 24,251 |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | (788) |
| **នាថ្ងៃទី31 ខែធ្នូ** | **72,728** | **291,858** |
| **តម្លៃពិតគណនេយ្យ** | | |
| **នាថ្ងៃទី31 ខែធ្នូ** | **19,338** | **77,603** |

| | *កុំព្យូទ័រសូហ្វវែរ* | *ការសាងសង់កំពុងដំណើរការ* | *សរុប* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **2024** | | | | |
| **តម្លៃដើម** | | | | |
| នាថ្ងៃទី1 ខែមករា | 63,250 | 17,517 | 80,767 | 329,933 |
| ការផ្ទេរ | 17,517 | (17,517) | - | - |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | (4,846) |
| **នាថ្ងៃទី31 ខែធ្នូ** | **80,767** | **-** | **80,767** | **325,087** |
| **ដកៈ រំលស់បង្គរ** | | | | |
| នាថ្ងៃទី1 ខែមករា | 63,250 | - | 63,250 | 258,376 |
| រំលស់ក្នុងការិយបរិច្ឆេទ *(កំណត់សម្គាល់លេខ 24)* | 3,432 | - | 3,432 | 13,972 |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | - | - | - | (3,953) |
| **នាថ្ងៃទី31 ខែធ្នូ** | **66,682** | **-** | **66,682** | **268,395** |
| **តម្លៃយោង** | | | | |
